

នៅជាប់អស់កល្បជានិច្ច



(6)

នេះគឺជាពាក្យរបស់លោក ដេវេក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> ឯលោកីយ៍នេះ និងសេចក្តីប៉ងប្រាថ្នារបស់វា
> នោះកំពុងកន្លងទៅ
> តែអ្នកណាដែលធ្វើតាមព្រះហឫទ័យព្រះ
> នោះនឹងនៅជាប់អស់កល្បជានិច្ច។ [១ យ៉ូហាន ២:១៧]

យើងកំពុងរស់នៅក្នុងពិភពលោកដែលតែងតែផ្លាស់ប្តូរជានិច្ច
ហើយវាមិននៅស្ថិតស្ថេរជាអចិន្ត្រៃយ៍នោះទេ។
គ្មានអ្វីដែលយើងមើលឃើញនេះ
នឹងស្ថិតស្ថេរនៅជាអចិន្ត្រៃយ៍នោះទេ។ មហិច្ឆតា បំណងប្រាថ្នា
តណ្ហារបស់មនុស្សនៅក្នុងពិភពលោកនេះ
នឹងត្រូវលិចលង់ទៅតាមពេលវេលា
ហើយអ្វីៗខាងសាច់ឈាមនឹងត្រូវកន្លងផុតទៅដែរ។

មានអំណាចដែលធ្វើការនៅក្នុងពិភពលោកនេះ
អំណាចខាងព្រលឹងវិញ្ញាណ អំណាចខាងសម្ភារៈ
ដែលមានអំណាចខ្លាំងជាងយើង
មានអំណាចដែលយើងមិនអាចគ្រប់គ្រងបាន។
យើងគ្រាន់តែដូចជាដំណក់ទឹកតូចមួយ
នៅលើផ្ទៃទឹកទន្លេដែលត្រូវបានហូរនាំទៅឆ្ងាយប៉ុណ្ណោះ។
តើមានផ្លូវណាមួយដែលអាចស្វែងរកភាពអចិន្ត្រៃយ៍បាន?

តើមានផ្លូវណាមួយដែលអាចស្វែងរកសុវត្ថិភាពបាន? បាទ
វាសាមញ្ញណាស់។
ពាក្យព្រះបន្ទូលដែលខ្ញុំអានទាំងនេះមានចម្លើយជាស្រេច។

> តែអ្នកណាដែលធ្វើតាមព្រះហឫទ័យព្រះ
> នោះនឹងនៅជាប់អស់កល្បជានិច្ច។

នៅចុងបញ្ចប់
មានតែព្រះហឫទ័យរបស់ព្រះទេដែលនឹងនៅជាប់អស់កល្បជានិច្ច។
នៅពេលដែលអ្វីៗផ្សេងទៀតបានដួលរលំ និងរសាត់ទៅឆ្ងាយបាត់
ហើយមិននៅស្ថិតស្ថេរជាអចិន្ត្រៃយ៍ និងមិនមានសុវត្ថិភាព
ធ្វើឱ្យយើងខកចិត្ត
ហើយប្រហែលជាមានការបញ្ឆោតយើងយ៉ាងណាក៏ដោយ។

មានការមួយដែលនឹងធ្វើឲ្យយើងមានសុវត្ថិភាព
នោះគឺជាព្រះហឫទ័យរបស់ព្រះ។ ព្រះទ្រង់គ្រប់គ្រង។
ទ្រង់មានអំណាចកំពូលលើសទាំងអស់។
ហើយប្រសិនបើអ្នករួបរួមខ្លួនអ្នកជាមួយនឹងព្រះហឫទ័យរបស់ព្រះ
ប្រសិនបើអ្នកធ្វើវាឱ្យក្លាយទៅជាគោលបំណងរបស់អ្នកនៅក្នុងជីវិត
ដោយធ្វើតាមព្រះហឫទ័យរបស់ព្រះ នោះអ្នកនឹងមានភាពរឹងមាំ

ហើយស្ថិតស្ថេរនៅជាអចិន្ត្រៃយ៍
និងមានសុវត្ថិភាពដូចជាព្រះហឫទ័យរបស់ព្រះដែរ។

កាល:ទេស:នឹងផ្លាស់ប្តូរ ពិភពលោកនឹងផ្លាស់ប្តូរ
ប៉ុន្តែព្រះហឫទ័យរបស់ព្រះនៅជាប់យ៉ាងរឹងមាំ នៅស្ថិតស្ថេរ
និងគ្មានអ្វីដែលអាចយកឈ្នះបានឡើយ
ហើយអ្នកក៏អាចធ្វើបានដូចជាព្រះហឫទ័យរបស់ព្រះដែរ
ប្រសិនបើអ្នកតាំងចិត្តធ្វើវា។

: WD-WFTW-006-KHM
: 24 Feb 2026
: derekprince.com/km/resources

